# របាយការណ៍បញ្ចប់ការដោះស្រាយវិវាទរបស់ការិយាល័យស៊ីអេអូ ៖ ករណីអាកាសយានដ្ឋាននៅកម្ពុជា-០១/ភ្នំពេញ

*របាយការណ៍នេះសង្ខេបអំពីដំណើរការដោះស្រាយវិវាទរបស់ការិយាល័យស៊ីអេអូ ទាក់ទងនឹងគម្រោងអាកាសយានដ្ឋានក្នុងប្រទេសកម្ពុជា (#21363) ដែលទទួលបានកិច្ចគាំទ្រពីសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)*

## សាវតា

### ការវិនិយោគរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)

Société Concessionnaire de l'Aéroport ("SCA") ទទួលបានសម្បទានរយៈពេល៤៥ឆ្នាំ[1] ពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើការរចនា ផ្តល់ហិរញ្ញប្បទាន សាងសង់ ថែទាំ និងធ្វើប្រតិបត្តិការអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ (PPIA) អាកាសយានដ្ឋានអន្តរជាតិសៀមរាប (SRIA) និង អាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ (SIA) ក្នុងប្រទេសកម្ពុជា។ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ស្ថិតនៅចម្ងាយ១០គីឡូម៉ែត្រ ភាគខាងលិចរាជធានីភ្នំពេញ។

នេះគឺជាគម្រោងមួយ ក្នុងចំណោមគម្រោងចំនួនពីរដំបូងគេបង្អស់ដែល IFC អនុវត្តជាមួយ SCA និង រួមមានការកែលម្អហេដ្ឋារចនាសម្ព័ន្ធ នៅក្នុងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ រួមទាំងការពង្រីកចម្ងាយ និង ទំហំទទឹងផ្លូវរត់ ការសាងសង់ផ្លូវ Taxiway មួយដែលស្របគ្នា ការពង្រីកបរិវេណចតយន្តហោះ និងសម្ភារៈបរិក្ខានៅក្នុងឃ្លាំង ព្រមទាំងការធ្វើទំនើបកម្ម ទៅលើឧបករណ៍ប្រតិបត្តិការរបស់អាកាសយានដ្ឋាន។

ការវិនិយោគរបស់ IFC រួមមានឥណទានរហូតដល់១០លានដុល្លារអាមេរិក។ គម្រោងនេះត្រូវបានកំណត់ចំណាត់ថ្នាក់ថាជាគម្រោងប្រភេទ ខ។ ឥណទានដែលបានផ្តល់ឱ្យក្រុមហ៊ុន SCA ត្រូវបានដកចំណាយ និង ប្រើប្រាស់ទាំងស្រុង ហើយ IFC បានបិទគម្រោងនេះក្នុងខែវិច្ឆិកា ឆ្នាំ២០១៨។



ព្រំប្រទល់រវាងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងសហគមន៍ជុំវិញ

### ពាក្យបណ្តឹង

ក្នុងខែមិថុនា ឆ្នាំ២០១៣ មានគ្រួសារចំនួន ៥៩ មកពីភូមិថ្មគោល និងភូមិព្រៃជីសាក់ ដោយមានកិច្ចគាំទ្រ និងជំនួយពីអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាមួយ ដែលមានឈ្មោះថា អង្គការសមធម៌កម្ពុជា បានដាក់ពាក្យបណ្តឹងមួយមកការិយាល័យស៊ីអេអូ។ ពាក្យបណ្តឹងបានលើកឡើងនូវបញ្ហាកង្វល់មួយចំនួនអំពីការធ្វើលទ្ធកម្មដីធ្លី និង ការបណ្តេញចេញដោយបង្ខំដែលអាចកើតឡើង ពាក់ព័ន្ធនឹងការអភិវឌ្ឍអាកាសយានដ្ឋាននេះ។ បញ្ហាជុំវិញការពិគ្រោះយោបល់ជាមួយសហគមន៍ និង ការត្រួតពិនិត្យឱ្យបានត្រឹមត្រូវ ក៏ត្រូវបានលើកឡើងនៅក្នុងពាក្យបណ្តឹងផងដែរ។ ដើមបណ្តឹងបានស្នើសុំឱ្យរក្សាអត្តសញ្ញាណរបស់ពួកគេជាការសម្ងាត់។

[1] រដ្ឋាភិបាលបានផ្តល់សម្បទានជូនក្រុមហ៊ុន SCA ចាប់ពីឆ្នាំ១៩៩៥។

## ការប៉ាន់ប្រមាណរបស់ការិយាល័យ ស៊ីអេអូ

ការិយាល័យ ស៊ីអេអូ បានកំណត់ថា ករណីនេះមានលក្ខខណ្ឌសមស្រប សម្រាប់ធ្វើការប៉ាន់ប្រមាណក្នុងខែមិថុនា ឆ្នាំ២០១៣ ហើយដំណើរបេសកកម្មដើម្បីធ្វើការប៉ាន់ប្រមាណ ត្រូវបានធ្វើឡើងក្នុងខែកក្កដា និង ខែវិច្ឆិកា ឆ្នាំ២០១៣។ ដំណើរការប៉ាន់ប្រមាណមានគោលបំណងបញ្ជាក់អំពីបញ្ហា និង កង្វល់ ដែលដើមបណ្តឹងបានលើកឡើង ព្រមទាំងជួយដល់ភាគីធ្វើការកំណត់ ថាតើពួកគេអាចដោះស្រាយបញ្ហានៅក្នុងពាក្យបណ្តឹង បានដែរឬទេ និង ដោះស្រាយដោយរបៀបណា។ ការិយាល័យ ស៊ីអេអូ មិនប្រមូលព័ត៌មាន ដើម្បីធ្វើការវិនិច្ឆ័យទៅលើអង្គសេចក្តីនៃពាក្យបណ្តឹងឡើយ។

ក្នុងអំឡុងពេលធ្វើការប៉ាន់ប្រមាណ ភាគីដែលរួមមានជាអាទិ៍ សហគមន៍រងផលប៉ះពាល់ ក្រុមហ៊ុន SCA និង ស្ថាប័នរាជរដ្ឋាភិបាល បានឯកភាពចូលរួមនៅក្នុងដំណើរការដោះស្រាយវិវាទមួយរបស់ការិយាល័យ ស៊ីអេអូ ដើម្បីខិតខំដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង ក្នុងលក្ខណៈមួយប្រកបដោយកិច្ចសហការ។ សេចក្តីសម្រេចនេះត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ប៉ាន់ប្រមាណរបស់ការិយាល័យ ស៊ីអេអូ ដែលបានផ្សព្វផ្សាយជាសាធារណៈក្នុងខែកុម្ភៈ ឆ្នាំ២០១៤។

## ដំណើរការដោះស្រាយវិវាទ

មុខងារផ្នែកដោះស្រាយវិវាទ របស់ការិយាល័យ ស៊ីអេអូ ផ្តល់នូវវេទិកាមួយក្រៅប្រព័ន្ធតុលាការ ពុំមានលក្ខណៈបដិភាគី និង អព្យាក្រឹត្យ ដែលភាគីអាចស្វែងរកដំណោះស្រាយគួរជាទីពេញចិត្តទាំងសងខាង ចំពោះបញ្ហាផ្នែកបរិស្ថាន និង សង្គម ដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង ព្រមទាំងជួយធ្វើឱ្យប្រសើរឡើងនូវលទ្ធផលគម្រោងជាក់ស្តែងនៅមូលដ្ឋាន។

សម្រាប់ដំណើរការដោះស្រាយវិវាទ ក្នុងករណីនេះ ការិយាល័យ ស៊ីអេអូ បានផ្តល់នូវសន្ទានកម្ម/ការសម្របសម្រួល និង បានរៀបចំកិច្ចប្រជុំដាច់ដោយឡែក និង កិច្ចប្រជុំពហុភាគីអ្នកពាក់ព័ន្ធរួមគ្នា ទៅតាមភាពចាំបាច់។ ការិយាល័យ ស៊ីអេអូ បានធ្វើការងារជាមួយភាគីដើម្បីជួយដល់ពួកគេឱ្យឯកភាពលើបញ្ហា ពាក់ព័ន្ធនឹងការរៀបចំដំណើរការសម្រាប់សន្ទានកម្មនេះ និង របៀបដែលសន្ទានកម្មនេះនឹងត្រូវធ្វើឡើង។

ភាគីចម្បងៗនៅក្នុងដំណើរការដោះស្រាយវិវាទនេះ រួមមាន៖

- រាជរដ្ឋាភិបាលកម្ពុជា តំណាងដោយគណៈកម្មាធិការដីធ្លី និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល (រលអស)
- ក្រុមប្រឹក្សាប្រជាពលរដ្ឋនៃសហគមន៍រងផលប៉ះពាល់ជុំវិញអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ (PPACAG)៖ សមាជិកសហគមន៍មូលដ្ឋាន ដែលជាអ្នកតំណាង និង ស្វែងរកមតិគាំទ្រ សម្រាប់សេចក្តីត្រូវការ ប្រយោជន៍ និង សិទ្ធិរបស់សហគមន៍រងផលប៉ះពាល់
- SCA៖ ប្រតិបត្តិករឯកជននៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

អ្នកពាក់ព័ន្ធបន្ថែមទៀតខាងក្រោម ក៏បានចូលរួមផងដែរ តាមរយៈការអញ្ជើញរបស់ភាគី៖

- សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)
- ក្រុមហ៊ុនហ្គ្រីនហ្គោល (GG)៖ ទីប្រឹក្សាពិគ្រោះយោបល់នាំមុខលើការងារដោះស្រាយផលប៉ះពាល់សម្រាប់ក្រុមហ៊ុន SCA និង គណៈកម្មាធិការដីធ្លី និង
- អង្គការមិនមែនរដ្ឋាភិបាល៖ អង្គការសមធម៌កម្ពុជា (EC) ក្រុមការងារសិទ្ធិលំនៅដ្ឋាន (HRTF) និង សមាគមធាងត្នោត (STT) ដែលផ្តល់ដំបូន្មាន កិច្ចគាំទ្រ និងការកសាងសមត្ថភាពជូនសហគមន៍រងផលប៉ះពាល់។



កិច្ចប្រជុំពហុភាគីអ្នកពាក់ព័ន្ធ សម្របសម្រួលដោយការិយាល័យ ស៊ីអេអូ

លទ្ធផលការងារនៃការសម្របសម្រួលដោះស្រាយវិវាទ

## ១. ការឯកភាពលើ "គ្មានការបណ្តេញចេញ"

លទ្ធផលដំបូងមួយនៃដំណើរការនេះ គឺរដ្ឋាភិបាល ក្រុមហ៊ុន SCA និង ក្រុមហ៊ុនហ្វ្រីនហ្គោល បានឯកភាពពិចារណាអំពីការរចនាគម្រោងដោយឡែក ដែលអាចធ្វើទៅរួច។ ការធ្វើបែបនេះនឹងជៀសវាងបាន ឬ កាត់បន្ថយឱ្យបានជាអតិបរមានូវការជម្លៀសជារូបវន្ត និង/ឬ ផ្នែកសេដ្ឋកិច្ច និងស្របពេលជាមួយគ្នានោះក៏រក្សាបានផងដែរ នូវតុល្យភាពផ្នែកបរិស្ថាន សង្គម និង ថ្លៃចំណាយ ព្រមទាំងប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ដោយផ្តោតយកចិត្តទុកដាក់ជាក់លាក់ ចំពោះផលប៉ះពាល់លើជនក្រីក្រ និងជនងាយរងគ្រោះ។ បន្ទាប់ពីមានកិច្ចព្រមព្រៀងនេះ រាជរដ្ឋាភិបាលបានប្រកាសថានឹងមិនមានការជម្លៀសដោយបង្ខំឡើយ ហើយពួកគេនឹងអនុវត្តតាមស្តង់ដារសមិទ្ធិកម្មជាធរមានរបស់ IFC។[2]

កាលពីខែមិថុនា ឆ្នាំ២០១៦ ខណៈពេលដែលផែនការដោះស្រាយផលប៉ះពាល់ (RAP) កំពុងត្រូវបានពិនិត្យសម្រេចរាជរដ្ឋាភិបាលកម្ពុជា បានប្រកាសថានឹងពុំមានការដោះស្រាយផលប៉ះពាល់ឡើយ ហើយផែនការដោយឡែកសម្រាប់សាងសង់អាកាសយានដ្ឋានថ្មី នៅឯទីតាំងផ្សេងកំពុងត្រូវបានពិនិត្យ។

[2] សូមមើលកំណត់ហេតុកិច្ចប្រជុំក្រុមការងារបច្ចេកទេស ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០១៤ ដែលអាចរកមើលបាននៅឯ https://bit.ly/3arlywE, បានចូលមើលនៅ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០។

## ២. លើកកម្ពស់ការចែករំលែកព័ត៌មាន និងការពិគ្រោះយោបល់



ផ្ទាំងប៉ាណូសម្រាប់ផ្តល់ព័ត៌មានដែលត្រូវបានដាក់តាំងបង្ហាញក្នុងភូមិថ្មគោល

នៅពេលដំបូងនៃដំណើរការនេះ ភាគីក៏បានឯកភាពចូលរួមនៅក្នុងការពិគ្រោះយោបល់ ទាក់ទងនឹងអាកាសយានដ្ឋានលើប្រធានបទដូចជា ការវាយតម្លៃដីធ្លី ការគណនាតម្លៃជំនួស ទីតាំងសម្រាប់ការតាំងទីលំនៅថ្មី និង ភាពអនុលោមទៅនឹងបទដ្ឋាន និងលក្ខខណ្ឌតម្រូវរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO) ព្រមទាំងប្រធានបទដទៃទៀត។ ភាគីបានឯកភាពរៀបចំដាក់បង្ហាញប៉ាណូព័ត៌មាន នៅតាមសហគមន៍រងផលប៉ះពាល់ជាសក្តានុពល។

IFC បានឯកភាពចែករំលែកព័ត៌មាន អំពីការអនុវត្តល្អបំផុតពាក់ព័ន្ធនឹងការដោះស្រាយផលប៉ះពាល់ និង ផ្តល់ព័ត៌មានព្រមទាំងដំបូន្មានទាក់ទងនឹងការអនុវត្តស្តង់ដារសមិទ្ធិកម្ម។ ព្រឹត្តិការណ៍នានា រួមមានកិច្ចប្រជុំជាមួយអង្គការមិនមែនរដ្ឋាភិបាល ការចូលរួមនៅក្នុងកិច្ចប្រជុំពហុភាគីអ្នកពាក់ព័ន្ធការពិគ្រោះយោបល់ដាច់ដោយឡែកជាមួយក្រុមហ៊ុន SCA និងគណៈកម្មាធិការដីធ្លី និង ការរៀបចំសិក្ខាសាលាមួយរយៈពេលពីរថ្ងៃ សម្រាប់អ្នកចូលរួមពីខាងរដ្ឋាភិបាល និងវិស័យឯកជន។

ក្រុមហ៊ុន SCA បានឯកភាពផ្តល់ព័ត៌មាន និង ពិគ្រោះយោបល់ជាមួយសហគមន៍រងផលប៉ះពាល់ និង អង្គការមិនមែនរដ្ឋាភិបាល ទាក់ទងនឹងការអនុវត្តស្របតាមបទដ្ឋាន

និងលក្ខខណ្ឌតម្រូវរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO)។

### ៣. ការកំណត់ព្រំប្រទល់តំបន់សន្តិសុខ និងតំបន់សុវត្ថិភាព

ការកំណត់ព្រំប្រទល់នេះ ត្រូវបានធ្វើឡើងដោយក្រុមការងារបច្ចេកទេសមួយ ដែលរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល (រលអស) បានបង្កើតឡើង ដោយឡែកការអង្កេតដើមគ្រាផ្នែកសង្គមសេដ្ឋកិច្ច និងការងារជំរឿន ត្រូវបានធ្វើឡើងដោយក្រុមហ៊ុនហ្គ្រីនហ្គោល ដោយមានការពិគ្រោះយោបល់ជាមួយ ក្រុមប្រឹក្សាប្រជាពលរដ្ឋនៃសហគមន៍រងផលប៉ះពាល់ជុំវិញអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ តំបន់សន្តិសុខ និងតំបន់សុវត្ថិភាពជុំវិញអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ គ្របដណ្តប់លើភូមិចំនួន៣ (ព្រៃជីសាក់ ថ្មគោល និងគោកចំបក់ ស្ថិតក្នុងសង្កាត់ចោមចៅ)[3] ត្រូវបានកំណត់ដោយផ្អែកលើបញ្ញត្តិស្តីពីសន្តិសុខ និង សុវត្ថិភាពរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO)។

### ៤. ជម្រើសដោយឡែកជំនួសឱ្យការដោះស្រាយផលប៉ះពាល់

ដើម្បីឱ្យស្របតាមបទដ្ឋានសុវត្ថិភាព និង សន្តិសុខរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ[4] និងដើម្បីជៀសវាងផលប៉ះពាល់ទៅលើសហគមន៍មូលដ្ឋាន រដ្ឋាភិបាល និងក្រុមហ៊ុន SCA បានឯកភាពសាងសង់របងសន្តិសុខខាងក្នុងថ្មីមួយនៅខាងក្នុងបរិវេណអាកាសយានដ្ឋានបច្ចុប្បន្ន និង ជួសជុលកែលម្អរបងអាកាសយានដ្ឋានចាស់នៅខាងក្រៅ។ ការសាងសង់របងខាងក្នុង និងការកែលម្អជញ្ជាំងរបងខាងក្រៅ បានបញ្ចប់ក្នុងខែមិថុនា ឆ្នាំ២០១៨។

[3] កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអន្តរក្រសួង ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៤ អាចរកមើលបាននៅង http://goo.gl/FVtVFA (ចូលមើលនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០)

[4] ចំណុចនេះហួសពីអាណត្តិការងាររបស់ការិយាល័យ ស៊ីអេអូ ក្នុងការផ្ទៀងផ្ទាត់ ឬ ផ្តល់មតិយោបល់ទៅលើភាពអនុលោមទៅនឹងបទដ្ឋានរបស់ ICAO ហើយរបាយការណ៍នេះគ្រាន់តែឆ្លុះបញ្ចាំងអំពីចេតនារបស់អ្នកពាក់ព័ន្ធក្នុងប្រទេស ដែលបានចូលរួមនៅក្នុងដំណើរការរបស់ការិយាល័យ ស៊ីអេអូ ប៉ុណ្ណោះ។



របងថ្មីខាងក្នុងអាកាសយានដ្ឋាន និង របងព្រំប្រទល់ខាងក្រៅដែលត្រូវបានកែលម្អ

## ការបិទករណី

កិច្ចប្រជុំបិទករណីជាស្ថាពរមួយ ត្រូវបានធ្វើឡើងនៅភ្នំពេញ កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ដោយមានការចូលរួមពីក្រុមប្រឹក្សាប្រជាពលរដ្ឋនៃសហគមន៍រងផលប៉ះពាល់ជុំវិញអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ក្រុមហ៊ុន SCA សារជីវកម្មហិរញ្ញវត្ថុអន្តរជាតិ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល។ មុនពេលកិច្ចប្រជុំ អ្នកចូលរួមបានធ្វើដំណើរទស្សនកិច្ចរួមគ្នាដើម្បីពិនិត្យមើលរបងថ្មីខាងក្នុងអាកាសយានដ្ឋាន និង ការសាងសាង់ជញ្ជាំងរបាំង។ កិច្ចប្រជុំនេះបានផ្តល់ឱកាសដល់អ្នកពាក់ព័ន្ធនានា ដើម្បីលើកឡើងអំពីការយល់ឃើញផ្សេងៗគ្នារបស់ពួកគេចំពោះដំណើរការ និង លទ្ធផល ព្រមទាំងការផ្តល់មតិយោបល់ត្រឡប់ជូនការិយាល័យ ស៊ីអេអូ។

នៅឯកិច្ចប្រជុំបិទករណីនេះ សមាជិកសហគមន៍មកពីក្រុមប្រឹក្សាប្រជាពលរដ្ឋ នៃសហគមន៍រងផលប៉ះពាល់ជុំវិញអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ បានកត់សម្គាល់អំពីសារៈសំខាន់នៃការទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី សម្រាប់អ្នកដែលបន្តរស់នៅក្បែរព្រំប្រទល់អាកាសយានដ្ឋាន ជាពិសេសដោយសារប្រជាពលរដ្ឋមួយចំនួន បានបង្ហាញឱ្យឃើញអំពីការភ័យខ្លាចថាពួកគេអាចមានការដោះស្រាយផលប៉ះពាល់ឱ្យប្តូរទីលំនៅថ្មី នៅថ្ងៃណាមួយក្នុងពេលអនាគត។ ពួកគេបានដកស្រង់កំណត់ហេតុកិច្ចប្រជុំលើកចុងក្រោយរបស់គណៈកម្មាធិការដីធ្លី កាលពីថ្ងៃទី១៩ ខែ

សីហា ឆ្នាំ២០១៩ ដែលមានការឯកភាពថារដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលនឹងផ្តល់ឯកសារ ដែលរួមមានប្លង់បញ្ជាក់ទីតាំងរបស់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ជូនទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីរៀបចំនីតិវិធីផ្តល់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ។ ការិយាល័យ ស៊ីអេអូ បានកត់សម្គាល់ថាដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធដីធ្លី គឺគ្រប់គ្រងដោយរដ្ឋភិបាល និង នៅពេលដែលពុំមានការដោះស្រាយផលប៉ះពាល់ ពាក់ព័ន្ធនឹងគម្រោងរបស់ IFC ការិយាល័យ ស៊ីអេអូ បានលើកទឹកចិត្តសមាជិកសហគមន៍ ឱ្យទាក់ទងទីភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធ រួមមានរដ្ឋាភិបាលមូលដ្ឋាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

មេរៀនបទពិសោធន៍ និងការយល់ដឹង

## ភាពច្នៃប្រឌិត និងភាពបត់បែននៅក្នុងការរចនាដំណើរការ

ករណីភាគច្រើនរបស់ការិយាល័យ ស៊ីអេអូ ដែលឆ្លងកាត់ដំណើរការដោះស្រាយវិវាទ អនុវត្តតាមគំរូសន្ទានកម្មបែបប្រពៃណី ដោយមានសន្ទានការីមួយរូបដែលមានភាពវិជ្ជាជីវៈ និងអព្យាក្រឹត្យ ជាអ្នករៀបចំកិច្ចប្រជុំដោយឡែក និងកិច្ចប្រជុំរួមគ្នាជាមួយភាគី។ ប្រសិនបើមានការឯកភាពព្រមព្រៀងគ្នាចំណុចព្រមព្រៀងទាំងនោះ នឹងត្រូវបានកត់ត្រាជាលាយលក្ខណ៍អក្សរ និងចុះហត្ថលេខាដោយភាគី និង ក្រោយមកការអនុវត្តចំណាត់ការដែលបានឯកភាពគ្នា ត្រូវបានត្រួតពិនិត្យដោយការិយាល័យ ស៊ីអេអូ។

នៅក្នុងករណីនេះ ការិយាល័យ ស៊ីអេអូ បានធ្វើការងារជាមួយភាគី ដើម្បីបង្កើតអភិក្រមមួយដែលកាន់តែមានភាពបត់បែន ដោយពិចារណាទៅលើបរិបទជាក់លាក់នៃករណីអាកាសយានដ្ឋានកម្ពុជា រួមទាំងការដែលត្រូវគោរពអធិបតេយ្យភាពរបស់រាជរដ្ឋាភិបាលកម្ពុជាទាំងស្រុង ចំនួនអ្នកពាក់ព័ន្ធដែលត្រូវបង្កលក្ខណៈឱ្យចូលរួម និង សំណើរបស់ដើមបណ្តឹងដំបូង ដែលបានស្នើសុំឱ្យរក្សាអត្តសញ្ញាណរបស់ពួកគេជាការសម្ងាត់។ ដំណើរការនេះភាគច្រើនរួមមានកិច្ចប្រជុំដោយឡែក កិច្ចប្រជុំទ្វេភាគី និង យូរៗម្តង ក៏មានកិច្ចប្រជុំពហុភាគីអ្នកពាក់ព័ន្ធទ្រង់ទ្រាយធំដែលត្រូវបានរៀបចំ និង សម្របសម្រួលដោយការិយាល័យ ស៊ីអេអូ ផងដែរ។ ពុំមានកិច្ចព្រមព្រៀងដែលត្រូវបានចុះហត្ថលេខាជាផ្លូវការរវាងភាគីឡើយ។ បញ្ហាត្រូវបានលើកយកមកពិភាក្សា និង នៅពេលដែលភាគីមួយ ឬ ច្រើន បានឯកភាពទៅនឹងចំណាត់ការជាក់លាក់ ចំណាត់ការទាំងនោះត្រូវបានយកមកអនុវត្ត។ សេចក្តីសម្រេចពាក់ព័ន្ធរបស់រដ្ឋាភិបាល ត្រូវបានកត់ត្រាទុកនៅក្នុងកំណត់ហេតុកិច្ចប្រជុំដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈ។ បើទោះបីជាដំណើរការដោះស្រាយវិវាទនេះ មិនមានលក្ខណៈដូចគ្នាទៅនឹងដំណើរការដោះស្រាយវិវាទទូទៅរបស់ការិយាល័យ ស៊ីអេអូ ក៏ដោយ ប៉ុន្តែគោលការណ៍នៃការចូលរួមដោយស្ម័គ្រចិត្ត និង ការធ្វើសេចក្តីសម្រេចចិត្តដោយផ្អែកលើមូលដ្ឋាននៃការទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ នៅតែត្រូវបានយកមកអនុវត្ត។ ដំណើរការនេះត្រូវបានរចនាឡើងដោយមានការពិគ្រោះយោបល់ ជាមួយគ្រប់ភាគីទាំងអស់ និងត្រូវបានអនុវត្តក្រោមមូលដ្ឋាននៃកិច្ចព្រមព្រៀងទ្វេភាគី។